សុន្ទរកថារបស់ **លោក ហ៊ីរ៉ូជី យ៉ូស៊ីហ៊ីរ៉ូ**

ឧបទូត/អនុប្រធានបេសកកម្មទូតជប៉ុនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយ
សម្រាប់គម្រោងទ្រង់ទ្រាយតូច-សន្តិសុខមនុស្សជាតិ របស់ប្រទេសជប៉ុន

១៤ កុម្ភៈ ២០១២

**សូមគោរព លោកស្រី មាស ចាន់ថុន ប្រធានក្រុមប្រឹក្សាឃុំកំពង់ហៅ**
**សូមគោរព អស់លោក លោកស្រី!**

ខ្ញុំមានសេចក្តីសោមនស្សរីករាយក្នុងការចូលរួមកម្មវិធីចុះហត្ថលេខានៅថ្ងៃនេះ លើកិច្ចសន្យាផ្តល់ជំនួយឥតសំណងជាមួយអ្នកតំណាងនៃក្រុមប្រឹក្សាឃុំកំពង់ហៅ សម្រាប់គម្រោងសាងសង់ផែបណ្តែតនៅក្នុងខេត្តកំពង់ឆ្នាំង។ ខ្ញុំក៏មានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំងផងដែរ ដែលការចុះហត្ថលេខាត្រូវបានធ្វើឡើងក្នុងឱកាសពិសេសនៃឆ្នាំ២០១៣ ជាខួបអនុស្សាវរីយ៍ទី៦០នៃទំនាក់ទំនងមិត្តភាពជប៉ុន-កម្ពុជា។

គម្រោងនេះមានគោលដៅជួយធ្វើឲ្យប្រសើរឡើងនូវការដឹកជញ្ជូនតាមផ្លូវទឹកនៅតាមដងទន្លេសាប ដែលមានសារៈសំខាន់សម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជននៅក្នុងតំបន់នេះ តាមរយៈការសាងសង់ផែបណ្តែតថ្មីមួយ និងជួសជុលនូវទីធ្លាឆ្លងសាឡាងដែលមានស្រាប់។ ជំនួយដែលនឹងផ្តល់ឲ្យសម្រាប់គម្រោងនេះមានទឹកប្រាក់ ២៩៨០៧ ដុល្លារអាមេរិក។ យើងរំពឹងថាគម្រោងនេះនឹងផ្តល់ផលប្រយោជន៍ច្រើនយ៉ាងដល់ប្រជាជនទូទាំង៩ឃុំ ដែលមានប្រជាជនប្រមាណ៥០០០០ កំពុងប្រើប្រាស់ដងស្ទឹងនេះ។ យើងក៏រំពឹងផងដែរថាកំពង់ផែថ្មីនេះនឹងជួយជំរុញសេដ្ឋកិច្ចនៅមូលដ្ឋានដោយសារការរីកចំរើននៃសកម្មភាពពាណិជ្ជកម្មនៅតាមដងស្ទឹងទាំងសងខាង។

ការអភិវឌ្ឍនៃវិស័យដឹកជញ្ជូនមានសារៈសំខាន់យ៉ាងខ្លាំងដើម្បីជួយជំរុញសកម្មភាពសេដ្ឋកិច្ច ក៏ដូចជាទំនាក់ទំនងសង្គម ហើយសម្រាប់បរិបទប្រទេសកម្ពុជាការដឹកជញ្ជូនតាមដងស្ទឹងមានប្រសិទ្ធភាពខ្ពស់ និងមានតម្លៃថោក និងស្ទើរតែមិនអាចជំនួសបានសម្រាប់ប្រជាជនមូលដ្ឋាន ដោយសារតែភាពសម្បូរណ៍បែបនៃផ្លូវទឹក។

រដ្ឋាភិបាលជប៉ុន ដោយទទួលស្គាល់អំពីសារៈសំខាន់នៃវិស័យដឹកជញ្ជូន ដើម្បីធានាដល់ការអភិវឌ្ឍនៃសេដ្ឋ-កិច្ច-សង្គមនៅប្រទេសកម្ពុជានោះ បាននិងកំពុងជួយដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាតាមរយៈការសាងសង់ផ្លូវថ្នល់ កំពង់ផែ និង ស្ពាន។ យើងជឿជាក់ថាគម្រោងនេះនឹងជួយធ្វើឲ្យប្រសើរឡើងនូវសន្តិសុខមនុស្សជាតិសម្រាប់ប្រជាពលរដ្ឋដែលងាយរងគ្រោះនៅតាមឃុំដែលពាក់ព័ន្ធ។

ខ្ញុំសង្ឃឹមថាគម្រោងដែលបានចុះហត្ថលេខានៅថ្ងៃនេះនឹងត្រូវបានអនុវត្តយ៉ាងរលូន និងដោយជោគជ័យដោយក្រុមប្រឹក្សាឃុំកំពង់ហៅ ហើយនឹងត្រូវបានថែទាំយ៉ាងល្អត្រឹមត្រូវដើម្បីឲ្យប្រជាជនអាចទទួលផលប្រយោជន៍ច្រើនបំផុតពីគម្រោងនេះ។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាគម្រោងនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជា។

សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់។